ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
ខេត្តកំពង់ស្ពឺ

លេខ : ...4050/២០..... **កប/កស្ព**

ជម្រាបមក

លោកនាយក ណានវ៉ាង ត្រាវ៉ែល ហ្គ្រុដស์ ឯក (ទីស័យ កាត់ដេរ)

អាសយដ្ឋាន ឃុំ/សង្កាត់ ត្រពាំងគង ក្រុង/ស្រុក/ខណ្ឌ សំរោងទង រាជធានី/ខេត្ត កំពង់ស្ពឺ

កម្មវត្ថុ ៖ ការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត

យោង ៖ លិខិតលេខ ២០១០២២៩១៩១ ចុះថ្ងៃទី២២ ខែ តុលា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ណានវ៉ាង ត្រាវ៉ែល ហ្គ្រុដស์ ឯក

សេចក្តីដូចបានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក/លោកស្រី ម្ចាស់ ឬនាយក ថាបន្ទាប់ពីបានពិនិត្យលើការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ក្រសួងសម្រេចអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៩៦នាក់ (ស្រី ១៩នាក់) ក្នុងចំនួនកម្មករនិយោជិតសរុប ៥៦៧នាក់ (ស្រី១១៥នាក់) រយៈពេលចំនួន ៦០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ក្នុងនោះ៖

-កម្មករនិយោជិតចំនួន ៩៦នាក់ (ស្រី ១៩នាក់) ទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗចំនួន ៤០ដុល្លារអាមេរិកក្នុងមួយខែ

ដើម្បីជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់ កម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ លោក/ លោកស្រី ម្ចាស់ ឬនាយក ត្រូវអនុវត្តការបើកប្រាក់ឧបត្ថម្ភរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមនីតិវិធីទូទាត់និងចំនួនដែលបានព្រមព្រៀងគ្នា។

ក្នុងករណី លោក/លោកស្រី ម្ចាស់ ឬនាយក ចង់ដំណើរការផលិតកម្ម ឬអាជីវកម្ម មុនកាលបរិច្ឆេទនៃការបញ្ចប់ការព្យួរកិច្ចសន្យាការងារ ត្រូវជូនដំណឹងជាលក្ខណ៍អក្សរមកក្រសួងឱ្យបានយ៉ាងតិច ២ថ្ងៃ (នៃថ្ងៃធ្វើការ)មុនថ្ងៃចូលធ្វើការ ហើយ លោក/លោកស្រី ត្រូវទទួលខុសត្រូវបង់ជូនកម្មករនិយោជិតទៅតាមចំនួនប្រាក់ឧបត្ថម្ភបានផ្ទេរកម្មករនិយោជិត ដែលបានចូលធ្វើការមុនកំណត់ទាំងនេះ។ ក្នុងករណីចាំបាច់ លោក/លោកស្រី អាចស្នើសុំបញ្ចប់ការព្យួរកិច្ចសន្យាការងារបុនកាលកំណត់បានចំនួន ១លើក។ ករណីលើសពី ១លើក លោក/លោកស្រី ត្រូវទទួលខុសត្រូវចេញប្រាក់ឧបត្ថម្ភជំនួសរាជរដ្ឋាភិបាលឱ្យទៅកម្មករនិយោជិតដែលនៅសល់រហូតដល់បញ្ចប់ការព្យួរកិច្ចសន្យាការងារ។

អាស្រ័យដូចនេះ សូម លោក/លោកស្រី ម្ចាស់ ឬនាយក បិទផ្សាយនូវលិខិតនេះ ជូនកម្មករនិយោជិតឱ្យបានជ្រាបគ្រប់ៗគ្នា
សូម លោក/លោកស្រី ម្ចាស់ ឬនាយក ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្ររំពីខ្ញុំ។★

ចម្លងជូន:
- ក្រសួងសង្គមកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងមហាផ្ទៃ(ស្រុកម្រាប់វិស័យទេសចរណ៍)
- ក្រសួងសុខាភិបាល(ម្រាប់ការការពារសុខភាពនិងសុវត្ថិភាពការងារ)
- ក្រសួងរ៉ែ និងថាមពល
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានធនធានក្រសួងសង្គមកិច្ច និងហិរញ្ញវត្ថុ
- បេឡាជាតិសន្តិសុខសង្គម
- ទីភ្នាក់ងារជាតិអភិវឌ្ឍន៍ការងារ
- ផ្នែកពាក់ព័ន្ធ

ថ្ងៃ ២ ១០ ខែ ១ ១ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
កំពង់ស្ពឺ ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០២០

ក.ប. រដ្ឋមន្ត្រី
ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ចឹក_ឫទ្ធិ